## កិច្ចប្រជុំលើកទី ១៨

## គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍

## ភ្នំពេញ ថ្ងៃទី ២០ ខែមេសា ឆ្នាំ២០១១

## សុន្ទរកថាស្វាគមន៍

## របស់ឧបនាយករដ្ឋមន្ត្រី **គាត ឈន់**

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធានទី១នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## ប្រធានគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍

- *លោកជំទាវ ឯកឧត្តម ជាសហសេវិកក្នុងរាជរដ្ឋាភិបាល*
- *លោកជំទាវ ឯកឧត្តម ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត និងតំណាងដៃគូអភិវឌ្ឍន៍*
- *លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក !*

១- ខ្ញុំមានសេចក្តីសោមនស្សរីករាយ និងសូមសំដែងការស្វាគមន៍យ៉ាងកក់ក្តៅចំពោះការអញ្ជើញចូលរួម របស់ *លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក* តំណាងក្រសួងនិងស្ថាប័នរបស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល ក្នុងកិច្ចប្រជុំលើកទី១៨នៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ (GDCC) នៅវិមានរដ្ឋាភិបាលនាឱកាសនេះ ។ មុននឹងចាប់ផ្តើមកិច្ចប្រជុំ ខ្ញុំសូមឆ្លៀតយកឱកាសនេះដើម្បីចូលរួមរំលែកទុក្ខយ៉ាងក្រៀមក្រំជាមួយរដ្ឋាភិបាលជប៉ុន និងប្រជាជនជប៉ុន ពិសេសជាមួយនឹងក្រុមគ្រួសារជនរងគ្រោះដែលបានបាត់បង់ជីវិតយ៉ាងអាណោចអាធម មហាទុក្ខវេទនា និងការខូចខាតទ្រព្យសម្បត្តិយ៉ាងធំធេង បង្កឡើងដោយរលកយក្ស«ស៊ូណាមិ» និងការរញ្ជួយដីដ៏ខ្លាំងក្លាបំផុត ដែលបានបោកបក់មកលើប្រទេសជប៉ុន កាលពីថ្ងៃទី ១១ ខែមិនា ឆ្នាំ២០១១ កន្លងមកនេះ ។ ខ្ញុំសង្ឃឹមថា ធនធាន និងសាមគ្គីភាពរបស់ប្រជាជនជប៉ុនដ៏អង់អាចក្លាហាន ប្រាកដជាអាចជំនះ ហើយអាចងើបឡើងផុតចេញពីផលវិបាកដែលបង្កើតឡើងដោយសោកនាដកម្មនេះ ។

*លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក !*

២- កិច្ចប្រជុំនេះគឺជាកិច្ចប្រជុំ GDCC លើកទី១៨ ពោលគឺមានរយៈពេលប្រមាណ៦ខែ បន្ទាប់ពីយើងបានជួបជុំគ្នាក្នុងកិច្ចប្រជុំ GDCC លើកចុងក្រោយកាលពីថ្ងៃទី ១៨ ខែតុលា ឆ្នាំ២០១០ ។ ក្នុងកំឡុងពេលនោះ យើងបានកត់សំគាល់ឃើញថា សេដ្ឋកិច្ចកម្ពុជាកំពុងបន្តស្តារនិងងើបឡើងវិញ ហើយកាលានុវត្តភាពក្នុងការស្រូបយកកំលាំងពលកម្មបន្ថែមទៀត និងការធ្វើឱ្យប្រសើរឡើងនូវសុខមាលភាពខាងផ្នែកសេដ្ឋកិច្ច និងសង្គមរបស់ប្រជាជនត្រូវបានពង្រឹងនិងពង្រីកបន្ថែមទៀត ។

៣- «វេទិកាសេដ្ឋកិច្ចកម្ពុជាលើកទី៤» ដែលបានប្រព្រឹត្តទៅនាថ្ងៃទី១៦-១៧ ខែកុម្ភៈ ឆ្នាំ២០១១ បានកំណត់យក ***«សេដ្ឋកិច្ចកម្ពុជាក្នុងបរិការណ៍ក្រោយវិបត្តិ- គោលនយោបាយឧស្សាហកម្ម : ជម្រើសឆ្ពោះទៅរកការអភិវឌ្ឍន៍***

***ប្រកបដោយចីរភាព*** ជាប្រធានបទស្នូលរបស់វេទិកា ។ ឆ្លងតាមការពិភាក្សា ខ្ញុំជឿជាក់ថា កម្ពុជាកំពុងឋិតលើមាគ៌ាមួយដ៏ត្រឹមត្រូវក្នុងដំណើរឆ្ពោះទៅរកកំណើនសេដ្ឋកិច្ចដ៏រឹងមាំ ដែលអាចផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនសម្រាប់ប្រជាជនកម្ពុជាទាំងមូល ។ ជាមួយនឹងកំណើនសេដ្ឋកិច្ចដែលអាចនឹងកើនឡើងខ្ពស់ជាង ៦ភាគរយនាឆ្នាំ២០១១នេះ ហើយស្ទើរគ្រប់វិស័យចូលរួមគាំទ្រដល់កំណើននេះ យើងសង្ឃឹមថា ផ្នែកឯកជនបាននិងកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរឆ្ពោះទៅសម្រេចគោលដៅនៃកំណើននេះ ។ ទន្ទឹមនឹងនេះដែរ វិស័យសាធារណៈក៏បានបង្ហាញអំពីវឌ្ឍនភាពយ៉ាងរឹងមាំគួរឱ្យកត់សំគាល់ផងដែរ ។ ចំណូលជាតិបានកើនឡើងប្រកបដោយចីរភាព ដែលអាចផ្តល់លទ្ធភាពឱ្យរាជរដ្ឋាភិបាលបង្កើនចំណាយសម្រាប់ការវិនិយោគសាធារណៈ ក្នុងខណៈពេលដែលយើងកំពុងអនុវត្ត «គោលនយោបាយឧស្សាហកម្ម» សម្រាប់ធ្វើពិពិធកម្មសេដ្ឋកិច្ច ទាំងខាងផលិតផល ទាំងខាងទីផ្សាររបស់យើង ។

*លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក !*

៤- កំណែទម្រង់ស្នូលរបស់រាជរដ្ឋាភិបាលមានវឌ្ឍនភាពគួរឱ្យកត់សំគាល់ ពិសេស កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ជាមួយនឹងផែនការអនុវត្តសម្រាប់រយៈពេល៣ឆ្នាំ ។ ទន្ទឹមនឹងនេះដែរ *យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ (ឆ្នាំ២០១១-២០១៥)* ត្រូវបានអនុមតិដោយគណៈរដ្ឋមន្ត្រី នាថ្ងៃទី១៨ ខែមិនា ឆ្នាំ២០១១កន្លងមក ។ ក្នុងបទអន្តរាគមន៍ខាងដើមរបស់ខ្ញុំ ដែលបានសង្កត់ធ្ងន់ទៅលើស្ថានភាពសេដ្ឋកិច្ចកម្ពុជាប្រកបដោយសុទិដ្ឋិនិយម យើងនៅជួបប្រទះបញ្ហាប្រឈមជាច្រើន ។ *យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ*បានឆ្លុះបញ្ចាំងអំពីកិច្ចប្រឹងប្រែងដ៏សំខាន់មួយរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តន៍ « ***យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី២*** និងក្នុងការធានាបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយគុណភាព ។ គឺស្ថិតលើមូលដ្ឋាននេះហើយដែលយុទ្ធសាស្ត្រជាតិនេះបានក្លាយជាប្រធានបទសម្រាប់ពិភាក្សាក្នុងកិច្ចប្រជុំនាពេលព្រឹកនេះ ក្នុងន័យរិះរកវិធានការសម្រាប់ផ្តល់ការគាំទ្រដល់ការអនុវត្តន៍ ក៏ដូចជាកំណត់តួនាទីរបស់តួអង្គទាំងអស់ដើម្បីគាំទ្រដល់ការអនុវត្តន៍អភិក្រមដែលមានចរិតពហុវិស័យនេះ ។

*លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក !*

៥- កិច្ចប្រជុំនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍របស់យើង ពិតជាមានការផ្សាភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងកិច្ចពិគ្រោះយោបល់កម្រិតគោលនយោបាយ នោះគឺវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា (CDCF) ។ យើងត្រូវរក្សាឱ្យបាននូវទំនាក់ទំនងនេះ ហើយក៏ត្រូវធានាឱ្យបានថា របៀបវារៈនៃកិច្ចប្រជុំរបស់យើងត្រូវផ្តោតលើការតាមដាន និងត្រួតពិនិត្យអំពីវឌ្ឍនភាពសំដៅឈានទៅសម្រេចឱ្យបាននូវការប្តេជ្ញានិងការព្រមព្រៀងទាំងឡាយ ដែលបានឯកភាពគ្នាក្នុងវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជានាថ្ងៃទី០២-០៣ ខែមិថុនា ឆ្នាំ២០១០ កន្លងមក ។

៦- ខ្ញុំពិតជាមានក្តីសោមនស្ស ដោយសង្កេតឃើញថារបៀបវារៈទី២របស់យើងនឹងពិភាក្សាលើវឌ្ឍនភាពនៃការធ្វើសុខដុមនីយកម្មរវាងការងារផែនការ ថវិកា និងហិរញ្ញប្បទានសហប្រតិបត្តិការ ។ ខ្ញុំជឿជាក់ថា វឌ្ឍនភាព

ក្នុងការរៀបចំផែនការយុទ្ធសាស្រ្តថវិកា (Budget Strategic Plan-BSP) ដែលនេះគឺជាផ្នែកស្នូលមួយនៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ- ដំណាក់កាលទី២ នឹងអាចនាំយើងឈានទៅសម្រេចគោលដៅនៃការធ្វើសុខដុមនីយកម្មនេះ ។ សហសេវិកដែលអញ្ជើញមកពីក្រសួងផែនការនឹងផ្តល់ទស្សនទានជាយុទ្ធសាស្រ្ត រយៈពេលវែងស្តីពីការធ្វើសុខដុមនីយកម្មរវាងការរៀបចំផែនការនិងថវិកាឱ្យមានសង្គតិភាពជាមួយគ្នា ដើម្បីគាំទ្រដល់ការអនុវត្តន៍ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ-បច្ចុប្បន្នកម្ម តាមរយៈអភិក្រមស៊ីសង្វាក់គ្នាក្នុងដំណើរការរៀបចំផែនការនិងថវិកា ដែលត្រូវរំលេចឱ្យឃើញនូវហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផងដែរ ។

*លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក !*

៧- របៀបវារៈទី៣ ដែលជារបៀបវារៈចុងក្រោយនៃកិច្ចប្រជុំរបស់យើងនឹងពិភាក្សាលើទម្រង់ និងដំណើរការនៃការគ្រប់គ្រងកិច្ចប្រជុំរបស់គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ។ ក្នុងឋានៈខ្ញុំជាប្រធាននៃគណៈកម្មាធិការនេះ ខ្ញុំបានដឹកនាំគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ចាប់ពីកិច្ចប្រជុំលើកដំបូង នាថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៤ កន្លងមក ហើយខ្ញុំសង្កេតឃើញថា ដំណើរការនៃយន្តការភាពជាដៃគូរបស់យើងមានការកែលំអជាច្រើន ។ ទន្ទឹមនឹងនេះ ខ្ញុំសូមស្វាគមន៍ចំពោះកិច្ចខិតខំប្រឹងប្រែងទាំងឡាយដើម្បីបន្តធានាប្រសិទ្ធភាពនិងភាពសក្តិសិទ្ធនៃកិច្ចប្រជុំ CDCF ។ ឯកឧត្តម ឈៀង យ៉ាណារ៉ា ក្នុងឋានៈជាប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការនេះ នឹងជម្រាបជូនអង្គប្រជុំអំពីការគ្រប់គ្រងដំណើរការរបស់គណៈកម្មាធិការ និងលើកសំណើមួយចំនួនដើម្បីបង្កើនប្រសិទ្ធភាពនៃយន្តការនេះ ដោយឈរលើគោលការណ៍នៃភាពជាដៃគូដែលជាមគ្គុទេសក៍សម្រាប់ណែនាំការងាររបស់យើង ។

៨- ខ្ញុំជឿជាក់ថាកិច្ចពិភាក្សានឹងដំណើរការប្រកបដោយស្មារតីស្ថាបនាលើការគ្រប់គ្រងយន្តការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍នេះ ដែលយើងទាំងអស់គ្នាបានចាត់ទុកថាជាយន្តការដ៏មានសារៈសំខាន់សម្រាប់ពិភាក្សាជាប្រចាំក្នុងកម្រិតគោលនយោបាយ ។ ដោយសារយន្តការនេះជាយន្តការអន្តរកម្មរវាងក្រុមការងារបច្ចេកទេសចម្រុះ - ដែលជាយន្តការសម្រាប់ពិគ្រោះយោបល់ក្នុងកម្រិតបច្ចេកទេស - និងវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា (CDCF) - ដែលជាវេទិកាកម្រិតគោលនយោបាយសម្រាប់កំណត់គោលដៅនិងការប្តេជ្ញានានាដែលពាក់ព័ន្ធនឹងកិច្ចការអភិវឌ្ឍន៍របស់ប្រទេស - ខ្ញុំយល់ថា គឺជាការចាំបាច់ណាស់ដែលយើងត្រូវព្យាយាមថ្លឹងថ្លែងដើម្បីធានាឱ្យមានតុល្យភាពរវាងកិច្ចពិភាក្សាកម្រិតបច្ចេកទេស និងកិច្ចពិភាក្សាកម្រិតគោលនយោបាយ ។ ជាការពិត សូចនាករតាមដានរួមគ្នាគឺជាក្របខ័ណ្ឌរួមសម្រាប់ពិភាក្សាក្នុងកិច្ចប្រជុំរបស់យើង ។ ក៏ប៉ុន្តែ យើងក៏អាចយកកិច្ចប្រជុំលើកនេះសម្រាប់ពិភាក្សានិងដោះស្រាយបណ្តាបញ្ហាប្រឈម និងអាទិភាពរបស់យើងផងដែរ ។ ខ្ញុំសូមស្វាគមន៍ចំពោះរាល់គំនិតនិងយោបល់របស់លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក នៅក្នុងកិច្ចពិភាក្សានាព្រឹកនេះ ។

*លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក !*

៩- ខ្ញុំសង្ឃឹមថាសុន្ទរកថាស្វាគមន៍របស់ខ្ញុំបានផ្តល់ជាក្របខ័ណ្ឌសម្រាប់កិច្ចពិភាក្សានាថ្ងៃនេះ ។ ខ្ញុំសូមស្នើ លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក ផ្តល់គំនិតនិងយោបល់ក្នុងន័យស្ថាបនា ដើម្បីធានាប្រសិទ្ធភាព និងលទ្ធផលខ្ពស់នៃកិច្ចពិភាក្សារបស់យើង ។

*សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់ !*